ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ........................

# សេចក្តីប្រកាសព័ត៌មាន

នាព្រឹកថ្ងៃព្រហស្បតិ៍ ១រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩ នៅវិមានមិត្តភាព ទីស្តីការគណៈរដ្ឋមន្ត្រី **សម្តេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងការពារជាតិ** តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី **នៃព្រះរាជាណាចក្រកម្ពុជា** នឹងអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីទទួលដំណើរមាតុភូមិនិវត្តន៍ របស់កងវិស្វកម្មលេខ៩៦៣ ពីសាធារណៈរដ្ឋលីបង់។

ពិធីនេះត្រូវបានរៀបចំឡើងជាកិច្ចស្វាគមន៍ និងអបអរសាទរចំពោះការវិលត្រឡប់វិញរបស់ កងវិស្វកម្មលេខ៩៦៣ ចំនួន១៨៤នាក់ ក្នុងនោះរួមទាំងនារី១៣នាក់ផងដែរ បន្ទាប់ពីបានសម្រេចភារកិច្ចក្នុងការបំពេញបេសកកម្មរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ (អ.ស.ប) អាណត្តិមួយឆ្នាំ នៅសាធារណៈរដ្ឋលីបង់ និងបានធ្វើមាតុភូមិនិវត្តន៍ មកដល់ព្រះរាជាណាចក្រកម្ពុជាវិញដោយសុវត្ថិភាព កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ ៕

*ថ្ងៃអង្គារ ១៤កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២*

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖០២៣ ៨៨៣ ២៧៤ អ៊ីម៉ែល៖ generalsec@mod.gov.kh